# ការកាត់ផ្តាច់សេវាទឹកភ្លើងតាមផ្ទះនឹងមានឆាប់ៗនេះ
## *ធ្វើកិច្ចការទាំងនេះដើម្បីការពារកុំឱ្យមានការកាត់ផ្តាច់សេវាទឹកភ្លើង!*

ថ្មីៗនេះ រដ្ឋ Pennsylvania បានកែជាថ្មីនូវបម្រាមរបស់ខ្លួន លើការកាត់ផ្តាច់សេវាទឹកភ្លើង គឺអតិថិជនមួយចំនួននឹងអាចទទួលបាន នូវការជូនដំណឹងកាត់សេវានោះ។ ទោះជាយ៉ាងនេះក្តី អតិថិជនដែលមានប្រាក់ចំណូលទាបគួរតែទទួលបានការការពារពីការកាត់ផ្តាច់សេវាទឹកភ្លើង ពួកគេធ្វើតាមជំហានជាក់លាក់មួយចំនួន។

ធ្វើកិច្ចការទាំងនេះភ្លាម ដើម្បីការពារក្រុមគ្រួសាររបស់អ្នក អំពីការកាត់ផ្តាច់សេវាទឹកភ្លើង៖

1) **ទូរសព្ទទៅក្រុមហ៊ុនផ្តល់សេវាទឹកភ្លើង។** ប្រាប់ពួកគេថាតើអ្នកនៅត្រឹម ឬក្រោមកម្រិតភាពក្រីក្រ 300% របស់សហព័ន្ធ។ នៅឆ្នាំ 2020 វាសំដៅលើចំណូលប្រចាំខែសរុប $3,190 ក្នុងមនុស្សម្នាក់និងចំណូលសរុប $6,550 ក្នុងមួយគ្រួសារដែលមានសមាជិក 4 នាក់ ) ។ ប្រាប់គេថា អ្នកនឹងដាក់ពាក្យស្នើសុំកម្មវិធីជំនួយសម្រាប់អ្នកដែលមានប្រាក់ចំណូលទាប។ ប្រសិនបើអ្នកមិនមានសិទ្ធិទទួលបានកម្មវិធីទាំងនោះទេ សូមសួរថាតើអ្នកអាចដាក់ពាក្យសុំកិច្ចព្រមព្រៀងបង់ប្រាក់មួយបានដែរឬទេ។

2) **ដាក់ពាក្យស្នើសុំកម្មវិធីជំនួយសម្រាប់អ្នកដែលមានប្រាក់ចំណូលទាប សម្រាប់សេវាទឹកភ្លើងរបស់អ្នក៖**

- *PECO៖ កម្មវិធីជំនួយដល់អតិថិជន (Customer Assistance Program, CAP) (Philadelphia)*
- *PGW៖ កម្មវិធីទំនួលខុសត្រូវរបស់អតិថិជន (Customer Responsibility Program, CRP) (Philadelphia)*
- *នៅខាងក្រៅទីក្រុង Philadelphia សូមទូរស័ព្ទទៅក្រុមហ៊ុនផ្តល់សេវាទឹកភ្លើងរបស់អ្នក*

3) **ដាក់ពាក្យស្នើសុំជំនួយឥតសំណង៖**

- *UESF (មូលនិធិសេវាកម្មសង្គ្រោះបន្ទាន់សម្រាប់សេវាទឹកភ្លើង (Utility Emergency Services Fund)) (Philadelphia)*
- *LIHEAP (កម្មវិធីជំនួយថាមពលតាមផ្ទះសម្រាប់អ្នកដែលមានប្រាក់ចំណូលទាប (Low Income Home Energy Assistance Program) - បើកនៅថ្ងៃទី 2 ខែវិច្ឆិកា ឆ្នាំ 2020) (នៅទូទាំងរដ្ឋ Pennsylvania)*

4) **ទូរសព្ទទៅក្រុមហ៊ុនផ្តល់សេវាទឹកភ្លើងរបស់អ្នក ដើម្បីបញ្ជាក់ថាអ្នកត្រូវបាន ការពារពីការកាត់ផ្តាច់ទឹកភ្លើង បន្ទាប់ពីអ្នកបានដាក់ពាក្យស្នើសុំជំនួយរួច**

- ប្រសិនបើក្រុមហ៊ុនផ្តល់សេវាទឹកភ្លើងមិនជួយអ្នក ប៉ុន្តែអ្នកគិតថាអ្នកគួរតែទទួលបាន នូវការការពារ **ចូរទូរស័ព្ទទៅការិយាល័យសេវាកម្មអតិថិជនរបស់ PUC តាមលេខ 800-692-7380**

ប្រសិនបើអ្នករស់នៅក្នុងទីក្រុង **Philadelphia** ហើយមានសំណួរអំពីការផ្លាស់ប្តូរនេះ ឬអ្នកកំពុងប្រឈមមុខនឹងការកាត់ផ្តាច់សេវាទឹកភ្លើង ទូរស័ព្ទទៅសេវាកម្មផ្លូវច្បាប់តាមសហគមន៍ **(Community Legal Services )** តាមលេខ 215-981-3700 ហើយទុកសារមួយផង។ សម្រាប់ព័ត៌មានបន្ថែមស្តីពីការដាក់ពាក្យសុំកម្មវិធីជំនួយ សូមចូលទៅកាន់គេហទំព័រ **www.clsphila.org/services/utility-bills/**

*ឯកសារនេះបានកែជាថ្មីនៅថ្ងៃទី 10/21/20 ។ ព័ត៌មានអាចផ្លាស់ប្តូរប្រសិនបើគណៈកម្មការសេវាទឹកភ្លើងសាធារណៈ (Public Utility Commission) ចេញសេចក្តីណែនាំបន្ថែម។*